# បុណ្យកឋិនទាន

ដោយព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
Website: www.hoksavann.org

ថ្ងៃទី២៤ តុលា ២០០៤

ពាក្យថាកឋិនប្រែថា រស់នៅដោយកម្រ ដោយវិគ្គហៈថកថតិ កិច្ចេន ជីវតីតិ ។ កឋិនោ ប្រែថាសភាវៈឯណារស់នៅបានដោយកម្រ សភាវៈនោះហៅថាកឋិន ប្រៀបដូចជាឈើស្ងួតដែលបុគ្គលកាត់ចេញចាកដើមហើយយកទៅបោះភ្ជាប់នឹងដីរមែងដុះលូតលាស់ ឬរស់នៅដោយកម្រយ៉ាងណា ឯកិច្ចនឹងកើតឡើងជាកឋិន ក៏បានដោយកម្រក៏យ៉ាងនោះដែរ ។ បុណ្យកឋិនទាននេះ មានពុទ្ធានុញ្ញាតទាក់ទងនឹងព្រះវិន័យ ដោយមានរឿងយ៉ាងសង្ខេបថា មានភិក្ខុ៣០អង្គជាអ្នកប្រតិបត្តិធម៌ក្នុងព្រៃនាំគ្នាទៅក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះពុទ្ធជាម្ចាស់មុនថ្ងៃចូលព្រះវស្សាតែទៅពុំទាន់ ក៏នាំគ្នារកសេនាសនៈ ទៅចាំវស្សានៅក្នុងជនបទមួយ ។ ពេលចេញព្រះវស្សា ទើបបន្តដំណើរទៅគាល់ព្រះពុទ្ធជាម្ចាស់ទាំងភ្លៀងទទឹកជោគ ។ ព្រះពុទ្ធបរមគ្រូបានសំណេះសំណាលប្រាស្រ័យជាមួយភិក្ខុទាំងនោះ ហើយសំដែងធម្មីកថាប្រារព្ធនូវសង្សារវដ្តមិនមានទីបំផុតប្រោសប្រទានដល់ភិក្ខុទាំងនោះ ។ លុះចប់ធម្មទេសនា ភិក្ខុទាំងនោះបានសំរេចព្រះអរហត្តទាំងអស់អង្គ ។ បន្ទាប់មក ព្រះអង្គមានព្រះតម្រិះថា បើព្រះអង្គបានតែងតាំងកឋិនត្ថារកិច្ចទុកក្នុងពេលមុន សមភិក្ខុទាំងនោះទុកចីវរមួយនៅនឹងកន្លែងជាប់តាមជាមួយខ្លួន តែស្បង់និងចីពរប៉ុណ្ណោះនឹងមានអត្តភាពស្រាល ហើយកឋិននេះ ព្រះពុទ្ធរាល់ព្រះអង្គតែងមានពុទ្ធានុញ្ញាតទុកដាក់សាវកពុំដែលខានផង ។ លុះព្រះតម្រិះដូច្នេះហើយទើបត្រាស់ហៅភិក្ខុទាំងឡាយអនុញ្ញាតនូវកឋិនត្ថារកិច្ចថា អនុជាធាមិ ភិក្ខវេវស្សំ វុដ្ឋានំ ភិក្ខូនំ នឋិនំ អត្ថរិតុំ អត្ថត កឋិនានំ វោ ភិក្ខវេ បញ្ចកប្បិស្សន្តិ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយដែលបាននៅចាំវស្សារួចហើយ ទទួលក្រាលកឋិន ។ ម្នាល់ភិក្ខុទាំងឡាយកាលបើភិក្ខុទាំងឡាយបានក្រាលកឋិនហើយ និងបានសំរេចនូវអានិសង្ស៥ប្រការ ។

បុណ្យកឋិនទាននេះ មានលក្ខណៈប្លែកពីទានដទៃ៥យ៉ាងគឺ ៖

១- ប្លែកដោយកាល ៖ កឋិនទាននេះ ព្រះសម្ពុទ្ធមានពុទ្ធានុញ្ញាតតែ២៩ថ្ងៃ គឺចាប់ពីថ្ងៃ១រោចខែអស្សុជដល់ថ្ងៃ១៥កើតខែកត្តិក ក្នុងរយៈកាលនេះ ទាយកចង់ធ្វើថ្ងៃណាក៏បាន វត្តមួយទទួលកឋិនបានតែម្តង បើមានម្ចាស់ច្រើនត្រូវធ្វើរួមគ្នាតែមួយថ្ងៃ ។

២- ប្លែកដោយវត្ថុ ៖ សំពត់ដែលអាចក្រាលកឋិនបាន គឺស្បង់ចីពរ ឬសង្ឃាដីណាមួយ ដែលបានកាត់ដេរត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។ បើទាយកវេរជាសំពត់សុទ្ធ ត្រូវភិក្ខុសង្ឃធ្វើឲ្យទៅជាត្រៃចីវរទាំង៣នេះណាមួយទើបក្រាលឡើងជាកឋិន ។

៣- ប្លែកដោយអំពើ ៖ ទាយកអ្នកធ្វើត្រូវធ្វើឲ្យត្រឹមត្រូវតាមវិធីបញ្ញត្តិ, ឯព្រះសង្ឃក៏គប្បីក្រាលគ្រងនិងអនុមោទនាឲ្យត្រឹមត្រូវតាមវិន័យបញ្ញត្តិដែរ ទើបឡើងជាកឋិនពេញលក្ខណៈ ។ ជំនុំសង្ឃដែលមានពី៥រូបឡើងទៅ ត្រូវប្រគល់សំពត់កឋិនដោយវិធីសូត្រទុតិយកម្មវាចា ។ បើសំពត់នោះទាយកបានធ្វើបុព្វករណៈទាំង៧ គឺការបោកគក់វាស់កាត់ដានដេរជ្រលក់ធ្វើពិន្ទុកប្បរួចហើយ គប្បីយកទៅក្រាលតែម្តង បើពុំទាន់បានធ្វើទេ គឺនៅជាសាច់សំពត់សុទ្ធ គប្បីព្រះសង្ឃនាំគ្នាធ្វើឲ្យរួចក្នុងថ្ងៃនេះ ។ បើក្រាលសង្ឃាដី ភិក្ខុមួយអង្គដែលជាអ្នកក្រាលនោះ គប្បីបញ្ចេញវាចាឲ្យសង្ឃឮច្បាស់ថា ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ ប្រែថា ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ ។ ចំណែកភិក្ខុអ្នកអនុមោទនាខ្ញីវស្សាជាង ត្រូវបញ្ចេញវាចាថា អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម ប្រែថា បពិត្រលោកម្ចាស់ដ៏ចំរើន កឋិនរបស់សង្ឃលោកម្ចាស់ក្រាលរួចហើយ ការក្រាលកឋិននេះប្រកបដោយធម៌ យើងទាំងឡាយសូមអនុមោទនា ។

៤- ប្លែកដោយបដិគ្គាហកៈ ៖ ភិក្ខុដែលអាចទទួលក្រាលគ្រងនិងអនុមោទនាកឋិនបាន លុះត្រាតែបានចាំវស្សាបីខែ ចូលជាបុរិមិកវស្សាហើយទទួលកឋិនបានតែម្តង ភិក្ខុដែលបានចាំវស្សាឬមានវស្សាដាច់ពុំអាចទទួលកឋិនបានឡើយ ។ ភិក្ខុដែលត្រូវបានជ្រើសរើសឲ្យក្រាលគ្រងកឋិនបាន គឺភិក្ខុដែលមានចីវរដាច់ដាច ហើយចេះនូវអានិសង្ស៥ចាំនូវមាតិកា៨ អនត្តតាការ២៤ អត្ថតាការ១៧ ។ មាតិកា៨ សំដៅយកការដោះកឋិន មានការសូត្រដករបស់សង្ឃដើម្បីឲ្យបានលាភដល់ភិក្ខុដែលមកដល់ថ្មី ដែលពុំបានទទួលកឋិនជាដើម ។ អនត្តតាការ២៤ សំដៅយកអាការៈដែលភិក្ខុមិនឡើងជាកឋិន មានសំពត់ដែលធ្វើពុំត្រឹមត្រូវតាមវិន័យជាដើម ។ អត្ថតាការ សំដៅយកអាការៈដែលភិក្ខុក្រាលបានពេញលក្ខណៈជាកឋិន គឺសំពត់ធ្វើត្រឹមត្រូវតាមវិន័យ ។

៥- ប្លែកដោយអានិសង្ស ៖ កឋិនទាននេះ បានអានិសង្សទាំងពីរផ្នែក គឺបានអានិសង្សទាយកអ្នកធ្វើ ឯផ្នែកព្រះសង្ឃអ្នកទទួលក្រាលគ្រងនិងអនុមោទនា រមែងបានអនិសង្ស៥ប្រការក្នុងរវាង៥ខែ ដោយសំរាលចាកអាបត្តិខ្លះ គឺទៅណាពុំបានលាភិក្ខុដែលនៅជាមួយគ្នាបាន, ធ្វើដំណើរមិនបាច់យកចីវរគ្រប់ប្រដាប់, ឆាន់គណៈភោជនបាន, ទុកអតិរេកចីវរបាន, មានសិទ្ធិត្រៃចីវរដែលកើតក្នុងអាវាសដែលខ្លួននៅនោះ ។ ឯទាយកអ្នកធ្វើ រមែងបានអានិសង្សដូចមានបាលីថា យេជនា សុខមិច្ឆន្តា ទត្វន កឋិនចីវរំ តេឋិទុក្ខា បមុញ្ចន្តិ ប៉ុណ្ណោះជាដើម ប្រែថា ជនទាំងឡាយឯណាប្រាថ្នានូវសេចក្តីសុខ ដោយឲ្យនូវចីវរដើម្បីកឋិន ជនទាំងឡាយនោះឯងរមែងរួចចាកទុក្ខក្នុងទេវតានិងមនុស្សទាំងឡាយ និងមិនទៅកើតក្នុងអបាយទាំងឡាយមាននរកជាដើមឡើយ ។

បុណ្យកឋិនទាននេះ បង្កើតបានជាសាមគ្គីភាពរបស់ជាតិខ្មែរយ៉ាងសំខាន់ណាស់ ។ មួយទៀត ក្រៅពីបុណ្យកុសលនេះ អំពើអាក្រក់តាមផ្លូវចិត្តក្នុងឱកាសនោះ មានលេងកំសាន្តដោយសិល្បៈផ្សេងៗផង ។ គ្របវត្តអារាមក្នុងប្រទេសនិងក្រៅប្រទេស ពុទ្ធសាសនិកជនខ្មែរតែងតែចូលរួមក្នុងបុណ្យកឋិនទាននេះដោយសទ្ធាជ្រះថ្លា ។៙